ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ: ១៧៦/២៣ រជ.ក

# របាយការណ៍ខែមិថុនា
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងទិសដៅខែកក្កដា ឆ្នាំ២០២៣

## I. ស្ថានភាពទូទៅ

ក្រសួង ស្ថាប័ន រាជធានី ខេត្ត នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបន្តសកម្មភាព របស់ខ្លួនទៅតាមទិសដៅគ្រោងទុក បើទោះប្រទេសជាតិ បាន និងកំពុងតែប្រឈមនឹងសភាពការណ៍វិវត្តន៍ថ្មី ដែលមិនអាចប៉ាន់ស្មានបាន ពាក់ព័ន្ធនឹងការជះឥទ្ធិពលពីការប្រែប្រួលនៃសភាពការណ៍ពិភពលោក ដែលមានទាំងវិបត្តិសេដ្ឋកិច្ច សង្គ្រាមរ៉ាំរ៉ៃនៅបណ្តាប្រទេសមួយចំនួន គ្រោះធម្មជាតិ( ទឹកជំនន់ ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ បំណាក់ដី ភ្លើងឆេះព្រៃ...) និងថែមទាំងគ្រោះមហន្តរាយដោយការរាតត្បាតដោយវីរុសកូវីដ-១៩ និងមេរោគបម្លែងថ្មី។

ក្រោយពីពិភពលោកកំពុងតែប្រយុទ្ធប្រឆាំងនឹងវិបត្តិជំងឺកូវីដ-១៩ មិនទាន់បានចប់ផង ក៏មានព្រឹត្តិការណ៍ថ្មីមួយទៀត ចាប់ពីខែ កុម្ភៈ ឆ្នាំ២០២២ មកដល់ពេលបច្ចុប្បន្ននេះមានការផ្ទុះសង្គ្រាមរវាងប្រទេសរុស្ស៊ី និងប្រទេសអ៊ុយក្រែន បានបង្កឱ្យមានវិបត្តិសេដ្ឋកិច្ចទូទាំងសកលលោក ដូចជាប្រេង និងឧស្ម័ន បានឡើងថ្លៃខ្ពស់ រហូតធ្វើឱ្យប្រទេសមួយចំនួនមានសេដ្ឋកិច្ចធ្លាក់ចុះយ៉ាងខ្លាំង និងមានវិបត្តិជំពាក់បំណុលគេដ៏ធ្ងន់ធ្ងរ ដែលមិនអាចដោះស្រាយបាន។

រាជរដ្ឋាភិបាលយើងបាន និងកំពុងតែ យកចិត្តទុកដាក់យ៉ាងខ្លាំង លើកិច្ចការពារអាយុជីវិតប្រជាពលរដ្ឋ ដែលបង្កដោយការរាតត្បាតដ៏ខ្លាំងក្លានៃវីរុសកូវីដ-១៩ និងផលប៉ះពាល់ដ៏ធំធេងលើ ជីវភាព និងសុខភាពប្រជាពលរដ្ឋ ព្រមទាំងសេដ្ឋកិច្ចសង្គមយ៉ាងធ្ងន់ធ្ងរ ជាភាពប្រឈមថ្មី និងដែលជះឥទ្ធិពលដល់ការអនុវត្តសកម្មភាពគ្រប់វិស័យ ធ្វើឱ្យរាំងស្ទះដោយអន្លើ នូវផែនការសកម្មភាពនានា ដែលបានគ្រោងទុក និងត្រូវបន្ថែមភារកិច្ចក្នុងការដោះស្រាយ ទប់ស្កាត់ផលប៉ះពាល់ លើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ចំណែកឯប្រជាជនយើង មួយចំនួននៅតែមើលស្រាលស្ថានភាព មិនស្តាប់ការអប់រំណែនាំ មិនតាមដានព័ត៌មានដែលមានប្រយោជន៍ តែបែរជាស្តាប់ និងជឿការអូសទាញ ភូតភរពីមេខ្យល់ ធ្វើឱ្យពួកគាត់ធ្លាក់ទៅក្នុងអំពើជួញដូរមនុស្ស និងខាតបង់ទាំងទ្រព្យសម្បត្តិ និងកម្លាំងកាយ រហូតដល់ធ្លាក់ខ្លួនឈឺដ៏ធ្ងន់ធ្ងរថែមទៀត។

អាជ្ញាធរ សមត្ថកិច្ច និងលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ និងអង្គការដៃគូ បានធ្វើសកម្មភាពយ៉ាងមមាញឹក ប្រចាំការនៅតាមព្រំដែនទទួលសង្គ្រោះពលករ ដែលវិលត្រឡប់តាមច្រកមិនផ្លូវការ ទាំងយប់ទាំងថ្ងៃ ពិនិត្យកម្តៅ និងផ្តល់សេវាសុខភាព អនុវត្តគោលការណ៍ចត្តាឡីស័កតាមវិធានសុខាភិបាល ផ្តល់អាហារ ត្រៀមមធ្យោបាយដឹកជញ្ជូន ឱ្យបានដល់លំនៅដ្ឋាន និងបន្តតាមដានស្ថានភាពសុខភាព ជីវភាព និងផ្តល់សេវាតាមតម្រូវការផ្សេងៗ និងបន្តតាមដានស្ថានភាព នៅពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍

ដែលពួកគាត់រស់នៅ។ លើសពីនេះទៅទៀត វិធានការអប់រំ បង្ការទប់ស្កាត់សកម្មភាពវិលត្រឡប់ទៅប្រទេសថៃវិញ ក្នុងអំឡុងពេលដែលមានការរឹតបន្តឹង ពីប្រទេសគោលដៅក្នុងវិធានការទប់ស្កាត់វិបត្តិកូវីដ-១៩ និងដោះស្រាយវិបត្តិសេដ្ឋកិច្ច ការបង្កើនការស៊ើបអង្កេតរកមេខ្យល់ជួញដូរមនុស្ស ក្នុងដំណាក់កាលនេះ ការផ្តល់សេវាជួយជនរងគ្រោះ និងជនងាយរងគ្រោះ ត្រូវបានធ្វើឡើងកាន់តែសកម្ម។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួលពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ អន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

#### ក.១. ការកសាងច្បាប់

- **ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី** បានដឹកនាំធ្វើសេចក្តីព្រាងច្បាប់ ស្តីពី "**ការពពោះជំនួស**"។
- **ក្រសួងយុត្តិធម៌** ៖
  - រដ្ឋសភាបានអនុម័តច្បាប់ស្តីពី "**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**" (MLA) (ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការណ៍ជាប្រញាប់ ដោយព្រះរាជក្រមលេខ នស/រកម ០៦២០/០២០ ចុះថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០២០)។
  - បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពី "**ការប្រឆាំងអំពើរត់ពន្ធមនុស្ស**"។

#### ក.២. សន្ធិសញ្ញា

- **ក្រសួងយុត្តិធម៌**
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសឡាវ បារាំង និងប្រទេសកូរ៉េខាងត្បូង ស្តីពី "**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**"
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសអង់គ្លេស ប៉េរូ និងប្រទេសឡាវ ស្តីពី "**ការបញ្ជូនទណ្ឌិត**"។

#### ក.៣. គោលនយោបាយ និងអនុស្សរណៈនៃការយោគយល់គ្នា

- **ក្រសួងទេសចរណ៍** ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាព ជាមួយអង្គការ Friends International។

#### ក.៤. លិខិតបទដ្ឋានគតិយុត្ត

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖** ធ្វើសេចក្តីព្រាងរៀបចំអនុក្រឹត្យ ស្តីពីរបបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

## ខ. ការបង្ការ ទប់ស្កាត់

### ១. តាមរយៈការលើកកម្ពស់ការយល់ដឹង

### ១.១. ការអប់រំដោយផ្ទាល់

#### ១.១.១. វេទិកាអន្តរសាសនា

លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តស្វាយរៀង បានរៀបចំវេទិកាអន្តរសាសនាស្តីពី "**ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**" នៅស្រុកចំនួន ០៣ គឺ នៅស្រុករមាសហែក ស្រុកកំពង់រោទិ៍ និងស្រុកស្វាយជ្រំ ដោយមាននិមន្តការអញ្ជើញចូលរួមពីព្រះសង្ឃ លោកគ្រូអាចារ្យវត្ត ថ្នាក់ដឹកនាំនៃគ្រីស្តសាសនា សាសនាមមហាយាន ឥស្លាមសាសនា និងបាហៃសាសនា លោកស្រីអភិបាលរងស្រុកទាំង០៣ មន្ទីរពាក់ព័ន្ធនៃក្រុមការងារទាំង០៦ កងកម្លាំងទាំង ៣ប្រភេទ សរុបប្រមាណ **៣៣៧**អង្គ/នាក់ (ស្រី **៥០**នាក់)។

#### ១.១.២. កិច្ចប្រជុំ និងវេទិកាផ្សព្វផ្សាយសាធារណៈ

នៅក្នុងខែមិថុនា ឆ្នាំ២០២៣នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "**ភូមិ-ឃុំ មានសុវត្ថិភាព**" និងកម្មវិធីផ្សេងៗ ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ និងប្រជាពលរដ្ឋ សរុបចំនួន **១៣.៥១៩**លើក មានអ្នកចូលរួមសរុបចំនួន **៦១៧.៣០៥**នាក់ (ធៀបនឹងខែឧសភាមានចំនួន **៦៤៦.៦៥៥**នាក់ គឺមានការថយចុះចំនួន **២៩.៣៥០**នាក់ ស្មើនឹង **៤,៧៥៤%** ក្នុងនោះស្ត្រីចំនួន **៣១០.៨៥៥**នាក់។ ដូចមានតារាងលម្អិតខាងក្រោម៖

**តារាងទិន្នន័យការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ**

| ល.រ | ក្រសួង ស្ថាប័ន | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | រាជធានី-ខេត្ត | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| ក្រសួង ស្ថាប័ន | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ៣២៤ | ១៨.៣៦០ | ៩.១២៥ | ៤៥៥ | ១៤.៥២៤ | ៨.០២០ |
| | សរុប ក្រសួង ស្ថាប័ន | ៣២៤លើក | ១៨.៣៦០នាក់ | ៩.១២៥នាក់ | ៤៥៥លើក | ១៤.៥២៤នាក់ | ៨.០២០នាក់ |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | | | |
| ២ | ខេត្តកណ្តាល | ៩២០ | ៤៥.៧៩៨ | ២១.៥៤៥ | ១.៤៣៤ | ១០៧.១៣១ | ៥៣.៥៧៦ |
| ៣ | ខេត្តបាត់ដំបង | ៩៣៥ | ៤២.៨៦៣ | ២២.៣១៥ | ៧៨៧ | ២៨.៦៨១ | ១៥.២០៧ |
| ៤ | ខេត្តពោធិ៍សាត់ | ៥៨៦ | ៦៧.៦៨៥ | ៣៧.០០២ | ១៦៩ | ៦.៦៣០ | ៣.១៤២ |
| ៥ | ខេត្តសៀមរាប | ៣៦៧ | ២៣.៩៤៨ | ១៤.០២១ | ១៣៧ | ៥.៤៣៤ | ៥.០៥៩ |
| ៦ | ខេត្តកំពង់ឆ្នាំង | ៨០១ | ២០.៩៥៨ | ១០.៤៦០ | ៤០១ | ១០.៣៣៦ | ៥.៦៤៤ |
| ៧ | ខេត្តកំពង់ចាម | ១.៧២០ | ៩០.៦៨២ | ៤៥.៦១៧ | | | |
| ៨ | ខេត្តព្រះសីហនុ | | | | | | |
| ៩ | ខេត្តព្រះវិហារ | ៤ | ៣៩២ | ១៥៣ | | | |
| ១០ | ខេត្តស្វាយរៀង | | | | ៦៣៦ | ២០.៩០១ | ១១.៧០៨ |
| ១១ | ខេត្តប៉ៃលិន | ៨៥ | ១.០៩៧ | ៣៣២ | ៣៨ | ១.៤៥២ | ៣២៦ |
| ១២ | ខេត្តកោះកុង | | | | ១១៣ | ១.៩៧៩ | ១.០២៤ |
| ១៣ | ខេត្តកំពត | ១៥ | ៨៦០ | ៤៤២ | ១៤ | ៨៧៤ | ៤២៥ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៤ | ខេត្តកំពង់ធំ | ២៦៩ | ១៥.៨៣៣ | ៧.៩០៤ | ៤៩ | ១.៧៦៦ | ១.០៣៧ |
| ១៥ | ខេត្តតាកែវ | ២២៧ | ៧.៦៩២ | ៣.៧៨៤ | ៧៦ | ២.៤៦៥ | ១.២០២ |
| ១៦ | ខេត្តក្រចេះ | ១៦ | ១.៥៩៦ | ៩២៤ | | | |
| ១៧ | ខេត្តកែប | ៣១ | ៦.៣៥៩ | ៣.០៩០ | ៥០ | ២.០៥០ | ១.២១៧ |
| ១៨ | ខេត្តកំពង់ស្ពឺ | ១៦ | ៣.៨៤៤ | ២.៤៧១ | | | |
| ១៩ | ខេត្តស្ទឹងត្រែង | | | | | | |
| ២០ | ខេត្តរតនគិរី | ២ | ១៩៨ | ៥៥ | ៣៩១ | ១៥.៥៦៤ | |
| ២១ | ខេត្តព្រៃវែង | ១១៩ | ៩.៨៦៤ | ៤.៦៨៥ | ១៧ | ១.៥៧៤ | ៨៨៩ |
| ២២ | ខេត្តត្បូងឃ្មុំ | ២.២៥០ | ៣២.១៤៩ | ១៤.៧១៩ | ៥១ | ៩៩៣ | ៦២១ |
| ២៣ | ខេត្តបន្ទាយមានជ័យ | ១១ | ៨៤១ | ៥២៧ | | | |
| ២៤ | ខេត្តឧត្តរមានជ័យ | ៣ | ៣.៩៣២ | ២.៥៨៧ | | | |
| ២៥ | ខេត្តមណ្ឌលគិរី | | | | | | |
| សរុប រាជធានី-ខេត្ត | | ៨.៣៧៧លើក | ៣៧៦.៥៩១នាក់ | ១៩២.៦៣៣នាក់ | ៤.៣៦៣លើក | ២០៧.៨៣០នាក់ | ១០១.០៧៧នាក់ |
| សរុបរួម | | ១៣.៥១៩ លើក | | ៦១៧.៣០៥ នាក់ | | ៣១០.៨៥៥ នាក់ | |

## ១.១.៣. ការផ្សព្វផ្សាយរបស់អង្គការដៃគូ

| អង្គការ | ចំនួនលើក | ចំនួនមនុស្ស | ចំនួនស្ត្រី |
|---|---|---|---|
| អង្គការជំណក់ទឹក (ខេត្តបន្ទាយមានជ័យ) | ០១ | ៣៥ | ២១ |
| អង្គការសាម៉ារីតាន់ភឺស (ខេត្តបន្ទាយមានជ័យ) | ០១ | ៧៥ | ៤០ |
| សរុប | **០២ លើក** | **១១០ នាក់** | **៦១ នាក់** |

## ១.២. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក

- **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** ផ្សព្វផ្សាយតាមរយៈផេកហ្វេសប៊ុក មានអ្នកទស្សនាចំនួន **៣.៣១៥**នាក់។
- **ខេត្តសៀមកំពង់ធំ៖** មន្ទីរពត៌មានខេត្ត ផ្សព្វផ្សាយតាមវិទ្យុ **១៨០**លើក។
- **ខេត្តព្រៃវែង៖** មន្ទីរពត៌មានខេត្ត ផ្សព្វផ្សាយតាមវិទ្យុ **៥០**លើក។

## ១.៣. ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖** លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួមជាវាគ្មិនកិត្តិយស ក្នុងកម្មវិធីកិច្ចពិគ្រោះយោបល់លើកទី២ ជាមួយសង្គមស៊ីវិល ស្តីពីការតាមដានលើសេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិមនុស្ស លើរបាយការណ៍តាមកាលកំណត់លើកទី៣-យេនឌ័រ រៀបចំដោយ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និងគណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ សរុបចំនួន **៦៤**នាក់។

## ១.៤. ការផ្សព្វផ្សាយតាមរយៈឧបករណ៍(IEC)

- **ខេត្តសៀមរាប៖ រដ្ឋបាលស្រុកពួក** បានធ្វើការចែកខិតប័ណ្ណ ដែលមានលេខទូរស័ព្ទសមត្ថកិច្ចសម្រាប់ទំនាក់ទំនងពេលមានហេតុការកើតឡើងជាយថាហេតុ ចំនួន**២៣៥**ខិតប័ណ្ណ។
- **ខេត្តបន្ទាយមានជ័យ៖** បានផ្តល់ការអប់រំ និងចែកខិត្តប័ណ្ណផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ពលករខ្មែរដែលវិលត្រឡប់ពីប្រទេសថៃមាន:

- **អង្គការសាម៉ារីតាន់ភឺស** ចំនួន **៧.៦៩២**នាក់ (ស្រី **២១៣**នាក់) កុមារ **៧៣**នាក់ (កុមារី **៣១**នាក់)។
- **អង្គការ** IOM ចំនួន **១.៣២០**នាក់ (ស្រី **២២**នាក់)។
- **អង្គការកល្យាណមិត្ត** ចំនួន **៣១៣**នាក់ (ស្រី **២១២**នាក់)។

• **ខេត្តបាត់ដំបង៖ អង្គការសាម៉ារីតាន់ភឺស៖** បានចែកខិត្តប័ណ្ណផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាពចំនួន **៦៦០**សន្លឹក និងខិត្តប័ណ្ណទប់ស្កាត់ការជួញដូរមនុស្សចំនួន **៤១៥**សន្លឹក សរុបចំនួន១.០៥០សន្លឹក ។

## ២. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

### ២.១. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក

• **ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត** បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកទៅក្រៅប្រទេសទាំងស្របច្បាប់ ទាំងមិនស្របច្បាប់ និងដាច់ការទាក់ទងសរុបចំនួន **២២៩.១៣៦**នាក់ (ស្រី**១០១.៤២៧**នាក់) អនីតិជន **៣.៦២៧**នាក់ (ស្រី **១.២៩៣**នាក់)៖
- ស្របច្បាប់ ចំនួន **១៧០.៦៨៦**នាក់ (ស្រី **៧៨.០៧៥**នាក់) អនីតិជន **២៨៥**នាក់ (ស្រី **៩០**នាក់)
- មិនស្របច្បាប់ចំនួន**៥៧.៧៧៨**នាក់(ស្រី**២៣.០៥៦**នាក់)អនីតិជន**៣.២៣៦**នាក់(ស្រី**១.១៧១**នាក់)
- ដាច់ការទាក់ទងចំនួន **៦៧២**នាក់(ស្រី **២៩៦**នាក់)អនីតិជន **១០៦**នាក់(ស្រី **៣០**នាក់)។

• **ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត** បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកត្រឡប់មកវិញដោយខ្លួនឯង ពីក្រៅប្រទេសទាំងស្របច្បាប់ និងមិនស្របច្បាប់ សរុបចំនួន **១២៥.២៥៣**នាក់ (ស្រី **៥៨.៤៥៤**នាក់) អនីតិជន **៤៩២**នាក់ (ស្រី **១៨០**នាក់)។

• **ខេត្តកែប៖** កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្ត បានធ្វើការងារបង្ការ ទប់ស្កាត់ពលរដ្ឋខ្មែរដែលធ្វើចំណាកស្រុកទៅប្រទេសថៃដោយខុសច្បាប់ចំនួន ០១លើក មនុស្សចំនួន **២៦២**នាក់ (ស្រី **១១៤**នាក់)។ បានសាកសួរព័ត៌មាន ដើម្បីស្វែងរកមេខ្យល់ និងធ្វើកិច្ចសន្យាអប់រំណែនាំកុំឱ្យធ្វើចំណាកស្រុកខុសច្បាប់ទៅក្រៅប្រទេសបន្តទៀត រួចបញ្ជូនទៅលំនៅដ្ឋានវិញ។

### ២.២. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ

▪ **អគ្គស្នងការដ្ឋាននគរបាលជាតិ**

• កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តកែប បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ចារកម្ម ដល់ម្ចាស់អាជីវកម្ម ផ្ទះសំណាក់ ហាងម៉ាស្សា ខារ៉ាអូខេ បានចំនួន **១៤**គោលដៅ មនុស្សចំនួន **១៤៧**នាក់ (ស្រី **១២២**នាក់)។

• កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង កំពត កោះកុង ក្រចេះ ព្រះវិហារ ព្រៃវែង និងតាកែវ បានល្បាតឃ្លាំមើលគោលដៅសង្ស័យ មានសកម្មភាពអាជីវកម្មផ្លូវភេទ ចំនួន **៣២**លើក។

### ២.៣. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

▪ **ក្រសួងមហាផ្ទៃ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (**ក្រុមការងារអនុវត្តន៍ច្បាប់**) បានធ្វើសម្ភាសន៍ពលរដ្ឋខ្មែរ និងជនបរទេសដែលបានដាក់ពាក្យសុំចុះបញ្ជីការរៀបអាពាហ៍ពិពាហ៍ចំនួន **២០៤**នាក់ (ស្រី **២១**នាក់) មាន **១៥**សញ្ជាតិ រួមមាន៖ ចិន **១០៩**នាក់ អាមេរិក **៣៨**នាក់ (ស្រី**០៧**នាក់) កូរ៉េខាងត្បូង ៣០នាក់ (ស្រី០៩នាក់) បារាំង ០៨នាក់ អូស្ត្រាលី ០៥នាក់ (ស្រី០៣នាក់) ថៃ ០២នាក់

(ស្រី០១នាក់) ឥណ្ឌូនេស៊ី០២នាក់ ប៉ែលហ្សិក ០២នាក់ អង់គ្លេស ០២នាក់ មីយ៉ាន់ម៉ា ០១នាក់ ម៉ូរីស ០១នាក់ វៀតណាម ០១នាក់(ស្រី) កាណាដា ០១នាក់ អ៊ីតាលី ០១នាក់ ម៉ាឡេស៊ី ០១នាក់ និងវាយតម្លៃបញ្ជូនឱ្យក្រុមការងារច្រកចេញ-ចូលតែមួយចំនួន ១១២នាក់ (ស្រី០៨នាក់)។ បានប្រមូលព័ត៌មានពីសុខទុក្ខនារីខ្មែរដែលរៀបការទៅរស់នៅប្រទេសកូរ៉េខាងត្បូង តាមរយៈការទំនាក់ទំនងតាមទូរស័ព្ទចំនួន ០២នាក់ សុខទុក្ខជាធម្មតា។

**៣. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ**

- **ខេត្តបន្ទាយមានជ័យ** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចងបដា និងផ្សព្វផ្សាយការទប់ស្កាត់ពលកម្មកុមារ ក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ នៅស្រុកព្រះនេត្រព្រះ លើកខ្លឹមសារៈ
  - ហាមក្មេងចូលទៅក្នុងបរិវេណខ្សែសង្វាក់ផលិតកម្ម ជនណាដែលនាំក្មេងចូលទៅក្នុងបរិវេណខ្សែសង្វាក់ផលិតកម្ម អាចប្រឈមនឹងបទល្មើសព្រហ្មទណ្ឌ និងការប្រើប្រាស់ពលកម្មកុមារនៅសិប្បកម្មផលិតឥដ្ឋ គឺអាចប្រឈមនឹងបទល្មើសព្រហ្មទណ្ឌ
  - ហាមឃាត់ដាច់ខាតការប្រើប្រាស់ទាសភាពបំណុល ដើម្បីដាក់បន្ទុកសេរីភាពការងារកម្មករ
  - ត្រូវមានអ្នកឃ្លាំមើលជាប្រចាំ និងហាមក្មេងចូលក្នុងបរិវេណខ្សែសង្វាក់ផលិតកម្ម ឬធ្វើការនៅក្នុងសិប្បកម្មផលិតឥដ្ឋ
  - ត្រូវរៀបចំកន្លែងស្នាក់នៅឱ្យឃ្លាតឆ្ងាយពីខ្សែសង្វាក់ផលិតកម្ម និងត្រូវមានរបងការពារសុវត្ថិភាពដែលខណ្ឌ ចែកបរិវេណខ្សែសង្វាក់ផលិតកម្ម និងកន្លែងស្នាក់នៅ
  - ហាមឃាត់ដាច់ខាតរាល់ទម្រង់នៃការកេងប្រវ័ញ្ចពលកម្មលើកុមារ និងការបង្ខំឱ្យកុមារធ្វើការដើម្បីដោះបំណុល។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១. ការងារអនុវត្តច្បាប់

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះទទួលបានពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត។

#### គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន **១៦**ករណី(ធៀបនឹងខែឧសភា មានចំនួន **១៨**ករណី ថយចុះចំនួន ០២ករណី) ស្មើនឹង**១១,១១%** ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងបានចំនួន **១៦**នាក់(ស្រី ០១នាក់) ក្នុងនោះជនសង្ស័យជាអនីតិជន ០២នាក់ និងជនបរទេស ០៣នាក់ (ចិន ហ្វីលីពីន អាមេរិក)។

សង្គ្រោះជនរងគ្រោះ ចំនួន **២៤**នាក់ មានៈ អាយុក្រោម១៥ឆ្នាំ **២០**នាក់ អាយុ១៥-១៧ឆ្នាំ **០២**នាក់ និងអាយុ១៨ឆ្នាំឡើង ០២នាក់ ប្រគល់ឱ្យមន្ទីរសង្គមកិច្ច ០៤នាក់ និងគ្រួសារចំនួន **២០**នាក់។ ក្នុងនោះចែកជាៈ

**១. ករណីអំពើជួញដូរមនុស្ស**

បង្ក្រាបបាន ០៥ករណី/០១ករណី (កើនឡើង ០៤ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ០៥នាក់ (ស្រី០១នាក់)ជនបរទេស ០៣នាក់។ សង្គ្រោះជនរងគ្រោះ ចំនួន ០៥នាក់ មានៈ អាយុក្រោម១៥ឆ្នាំ ០៥នាក់ ប្រគល់ឱ្យគ្រួសារចំនួន ០៥នាក់។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | បរទេស |
|---|---|---|---|---|
| -ការនាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ | ០១ | ០១ | ០១ | ចិន |
| -ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ០១ | ០១ | ០១ | |
| -អំពើលក់ដូរមនុស្ស | ០១ | ០១ | ០១ | ហ្វីលីពីន |
| -ការទិញពេស្យាចារកុមារ | ០២ | ០២ | ០២ | អាមេរិក |
| *សរុប* | *០៥ ករណី* | *០៥ នាក់* | *០៥ នាក់* | *០៣ នាក់* |

**២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ**

បង្ក្រាបបាន **១១**ករណី/**១៧**ករណី (ថយចុះ **០៦**ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន **១១**នាក់។ សង្គ្រោះជនរងគ្រោះ ចំនួន **១៩**នាក់ មាន: អាយុក្រោម១៥ឆ្នាំ **១៥**នាក់ អាយុ១៥-១៧ឆ្នាំ **០២**នាក់ និងអាយុ១៨ឆ្នាំឡើង **០២**នាក់ ប្រគល់ឱ្យមន្ទីរសង្គមកិច្ច **០៤**នាក់ និងគ្រួសារចំនួន **១៥**នាក់។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ |
|---|---|---|---|
| -សញ្ញារកម្មទាក់ទងនឹងពេស្យាចារកុមារ | ០១ | ០៤ | ០១ |
| -រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ | ០១ | ០១ | ០១ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៧ | ០៧ | ០៧ |
| -អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០២ | ០៧ | ០២ |
| *សរុប* | *១១ ករណី* | *១៩ នាក់* | *១១ នាក់* |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ឃ.១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

#### ឃ.១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**
  - **នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន** បានទទួល និងសម្ភាសន៍ជនរងគ្រោះដែលបានវិលត្រឡប់ពីប្រទេសចិន ចំនួន **៤៥**នាក់ (ស្រី **៤៤**នាក់)។ ជាលទ្ធផល រងគ្រោះដោយអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ **២៥**នាក់(ស្រី) និងស្នាក់នៅដោយខុសច្បាប់ **២០**នាក់។
  - **ខេត្តបន្ទាយមានជ័យ៖** ស្នងការនគរបាលខេត្ត ពលករចូលតាមច្រកអូរបីជាន់ ច្រកបឹងត្រកួន ច្រកចំបក់ និងច្រកអន្តរជាតិប៉ោតប៉ែត ចំនួន **២៩**លើក មនុស្សចំនួន **៥១៣**នាក់ (ស្រី**១៥៦**នាក់) អនីតិជន **៥៧**នាក់ (ស្រី **២៧**នាក់)។
  - **ខេត្តស្វាយរៀង៖ ស្នងការដ្ឋាននគរបាលខេត្ត** បានទទួលពលរដ្ឋខ្មែរពីសមត្ថកិច្ចវៀតណាម ចំនួន **០១**លើក មនុស្សចំនួន **០៩**នាក់ (ស្រី **០៧**នាក់ អនីតិជន)។

## III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

#### ក.១. ការងារបណ្តុះបណ្តាល

| សកម្មភាពរៀបចំវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|
| **ខេត្តសៀមរាបៈ** លេខាធិការដ្ឋាន គ.ខ.ប.ជ បានសហការជាមួយស្នងការដ្ឋាននគរបាលខេត្ត អង្គការមូលនិធិអេ២១ អង្គការជីវិតនៅកម្ពុជា អង្គការមូលនិធិអន្តរជាតិហាកា និងអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ បានរៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពលើការអនុវត្តច្បាប់ ស្តីពីយុត្តិធម៌អនីតិជន និងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាដោយសមស្រប និងការអនុវត្តតួនាទីភារកិច្ចរបស់គណៈកម្មាធិការ គ.ខ.ប.ជ ដល់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ ក្រុង ស្រុក និងឃុំ សង្កាត់។ | ០៧ | ៤៣៦ | ១៥៨ |
| **ខេត្តបាត់ដំបងៈ** លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការសម្ភាសបែបកោសល្យវិច័យ។ | ០១ | ៥២ | ២២ |
| **ខេត្តស្វាយរៀងៈ** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានសហការជាមួយក្រុមហ៊ុនចំនួន០២ បើកវគ្គបណ្តុះបណ្តាលដោយបានបញ្ជ្រាបការយល់ដឹងអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព រួមបញ្ចូលជាមួយនូវប្រធានបទស្តីពីបំនិនជីវិត អាហារូបត្ថម្ភ គ្រឿងញៀន និងសុវត្ថិភាពចរាចរណ៍ ការគ្រប់គ្រងសារជាតុគីមី ភាពជាអ្នកដឹកនាំក្រុមល្អដើម្បីបង្កើនផលិតភាពផលិតផល ច្បាប់ស្តីពីការងារ សុខភាព និងសុវត្ថិភាពការងារ និងការជួយសង្គ្រោះបឋម។ | ០៤ | ៧២ | ៤៣ |
| **ខេត្តស្ទឹងត្រែង** មន្ទីរកិច្ចការនារីខេត្តៈ | | | |
| - បើកវគ្គបណ្តុះបណ្តាល ស្តីពីកិច្ចការពារផ្លូវច្បាប់សម្រាប់សិទ្ធិស្ត្រី និងកុមារនៅកម្ពុជាដល់ក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រថ្នាក់ស្រុក។ | ០២ | ៧២ | ៤៤ |
| - បើកវគ្គបណ្តុះបណ្តាល ស្តីពីនីតិវិធីនៃការទប់ស្កាត់ការជួញដូរមនុស្ស ដល់អាជ្ញាធរ ឃុំ/ស្រុក/ក្រុង។ | ០៤ | ១០៨ | ៦២ |
| **សរុប** | ១៨ លើក | ៧៤០ នាក់ | ៣២៩ នាក់ |

### ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

#### ខ.១. កិច្ចប្រជុំក្នុងប្រទេស

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សៈ** លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញៈ
  - ដឹកនាំកិច្ចប្រជុំពិភាក្សា ស្តីពីការកែសម្រួលសៀវភៅមេរៀនកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ជាមួយក្រសួង-ស្ថាប័ន និងអង្គការដៃគូពាក់ព័ន្ធ នៅសាលប្រជុំ គ.ជ.ប.ជ។
  - ដឹកនាំកិច្ចប្រជុំពិភាក្សា ស្តីពីការរៀបចំកម្មវិធីផ្សព្វផ្សាយរបាយការណ៍ នៃការវិភាគពីស្ថានភាពការកេងប្រវ័ញ្ចលើកុមារនៅកម្ពុជា ជាមួយអង្គការ terre des hommes នៅកម្ពុជា នៅសាលប្រជុំ គ.ជ.ប.ជ។

- ដឹកនាំកិច្ចប្រជុំ ស្ដីពីស្ថានភាពអំពើជួញដូរមនុស្សនៅខេត្តស្ទឹងត្រែង សមាសភាពចូលរួមពី លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ លោកស្រីអភិបាលរងខេត្ត នាយករដ្ឋបាលសាលាខេត្ត ស្នងការរងខេត្ត នាយការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនខេត្ត តំណាងពីមន្ទីរសង្គមកិច្ច មន្ទីរអប់រំយុវជនកីឡា ប្រធានការិយាល័យច្បាប់ នៅខេត្តស្ទឹងត្រែង។
- ដឹកនាំកិច្ចប្រជុំប្រចាំមាសទី១ និងលើកទិសដៅឆមាសទី២ ឆ្នាំ២០២៣ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សមាសភាពចូលរួម អគ្គលេខាធិការ គ.ជ.ប.ជ អង្គការ ERIK IOM IJM Caritas Swiss Caritas Cambodia សេចក្ដីសង្ឃឹមពិភពលោក អង្គការមេត្រីអន្តរជាតិ UNICEF UNFPA CWCC Winrock អន្តរជាតិ Asian ACT សម្ពន័ចាប់ដៃ ណូមីណេតវីក អង្គការរតនៈ សមាគមអាជហុក នៅសាលប្រជុំ គ.ជ.ប.ជ។
- ដឹកនាំកិច្ចប្រជុំការត្រៀមរៀបចំទិវាជាតិអន្តរសាសនា ប្រឆាំងការជួញដូរមនុស្សលើកទី៧ ឆ្នាំ២០២៣ សភាសភាពចូលរួម អគ្គលេខាធិការ គ.ជ.ប.ជ តំណាងពីក្រសួងធម្មការសាសនា តំណាងពីគណៈដឹកនាំឥស្លាម តំណាងប្រិយសម្ព័ន្ធគ្រីស្ទបរិស័ទកម្ពុជា តំណាងមណ្ឌលសាសនាកាតូលិក សហគមន៍កាតូលិក និងអង្គការការីតាសកម្ពុជា នៅសាលប្រជុំ គ.ជ.ប.ជ។
- ដឹកនាំកិច្ចប្រជុំ ពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យ និងអនុសាសន៍របស់ក្រសួងការបរទេសអាមេរិចសម្រាប់កម្ពុជាពាក់ព័ន្ធនឹងកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៣ សមាសភាពចូលរួមពី លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ ឯកឧត្តម ហ៊ូ វុឌ្ឍី រដ្ឋលេខាធិការក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ឯកឧត្តម ញឹក វណ្ណារ៉ា រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន ឯកឧត្តម ណុប សុធនវិសុទ្ធ អគ្គនាយករង ក្រសួងយុត្តិធម៌ អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ និងអង្គភាពពាក់ព័ន្ធ នៅសាលប្រជុំ គ.ជ.ប.ជ។
- ដឹកនាំកិច្ចប្រជុំកម្រិតបច្ចេកទេស ប្រចាំឆមាសទី១ និងលើកទិសដៅឆមាសទី២ ឆ្នាំ២០២៣ គម្រោងសុវត្ថិភាពទេសន្តប្រវេសន៍នៅកម្ពុជា របស់អង្គការការីតាសស្វីស ដែលកំពុងអនុវត្តនៅមណ្ឌលទទួលពលករកំរៀងស្រុកកំរៀង ខេត្តបាត់ដំបង នៅសាលប្រជុំ គ.ជ.ប.ជ។
- ដឹកនាំកិច្ចប្រជុំជាមួយ អង្គការការីតាស់ស្វីស ដើម្បីពិនិត្យនិងដោះស្រាយបញ្ហាប្រឈមមួយចំនួនក្នុងគម្រោងសុវត្ថិភាពទេសន្តប្រវេសន៍នៅកម្ពុជា និងពិនិត្យរបាយការណ៍ សវនកម្មសផ្ទៃក្នុងរបស់គម្រោងផងដែរ នៅសាលប្រជុំ គ.ជ.ប.ជ។
- ដឹកនាំកិច្ចពិភាក្សាការងារជាមួយអង្គការអេ២១ ស្ដីពីគម្រោងថតវីដេអូឯកសារអប់រំពាក់ព័ន្ធស្ថានភាពរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសាលប្រជុំ គ.ជ.ប.ជ។

### ១.២. កិច្ចប្រជុំក្រៅប្រទេស

- **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖** លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ អមដំណើរដោយលោកស្រីវរសេនីយ៍ឯក **ថោង សុវត្ថិ** អនុប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ បានអញ្ជើញចូលរួមកិច្ចប្រជុំ នៅទីស្នាក់ការក្រសួងការបរទេស និងពាណិជ្ជកម្មប្រចាំរដ្ឋវិកតូរី ក្នុងគោលបំណងដើម្បីពិភាក្សា និងផ្លាស់ប្ដូរបទពិសោធន៍អំពី ការអនុវត្តការងារប្រឆាំងទាសភាពសម័យទំនើប និងអំពើជួញដូរមនុស្ស នៅប្រទេសអូស្ត្រាលី។

## ខ.៣. ការទទួលជួបពិភាក្សាការងារ

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖** លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ
  - បានទទួលជួបសម្តែងការគួរសមជាមួយអង្គការម៉ារីស៊ី និងធ្វើបទបង្ហាញ សុំអនុសាសន៍ណែនាំ និងកិច្ចគាំទ្រសហប្រតិបត្តិការភាពដៃគូរជាមួយ គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ។
  - បានជួបសំណេះសំណាលជាមួយអង្គការ World Hope International ដើម្បីពិភាក្សាអំពីការងារប្រឆាំងការជួញដូរមនុស្ស ដោយមានវត្តមាន លោកស្រី Emelita S. Goddard នាយកអង្គការ World Hope International ប្រចាំនៅកម្ពុជា លោក Sam Schleipman ប្រធានផ្នែកអភិវឌ្ឍន៍ និងកិច្ចសហប្រតិបត្តិការ និងលោក សួន សុវ៉ាសនា មន្ត្រីជាន់ខ្ពស់ផ្នែកត្រួតពិនិត្យ និងវាយតម្លៃ។
- **ខេត្តកណ្តាល៖** លោកជំទាវ **ហ៊ុន កុសនី** អភិបាលរង នៃគណៈអភិបាលខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ បានជួបពិភាក្សាជាមួយអង្គការសកម្មភាពដើម្បីកុមារ ស្តីពី" ការលើកកម្ពស់ការយល់ដឹង និងកម្មវិធីបណ្តុះបណ្តាលដែលបន្សីជាមួយផែនការសកម្មភាពប្រចាំឆ្នាំ២០២៣ របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើដូរមនុស្សខេត្តកណ្តាល"។

## ខ.៤. ការងារទស្សនកិច្ច

- **អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖**
  - លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានដឹកនាំប្រតិភូ មកពីប្រទេសស្វីសទៅធ្វើទស្សនកិច្ចនៅមណ្ឌលកំរៀង និងច្រកទ្វារព្រំដែនអន្តរជាតិដូងខេត្តបាត់ដំបង។ សមាសភាពមាន អគ្គលេខាធិការ គ.ជ.ប.ជ អង្គការការីតាស់ស្វីស សរុបចំនួន ១០នាក់។
  - លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ **សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ អមដំណើរដោយលោកស្រីវរសេនីយ៍ឯក **ថោង សុវត្ថិ** អនុប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ បានអញ្ជើញចូលរួមធ្វើទស្សនកិច្ចមជ្ឈមណ្ឌលអូស្ត្រាលី ប្រឆាំងការកេងប្រវ័ញ្ចកុមារ នៅប្រទេសអូស្ត្រាលី។

## គ. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ **៥៣**លើក មានអ្នកចូលរួមសរុប **៧៧៦**នាក់ (ស្រី **២៤២**នាក់) ក្នុងនោះមាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន **៣០**លើក និងលេខាធិការដ្ឋានរាជធានី ខេត្ត ចំនួន **២៤**លើក។(**ឧបសម្ព័ន្ធ១**)

# IV. ការសន្និដ្ឋានវាយតម្លៃ

## ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ **០៤ចំណុច** និងវិធានការ **០៦ចំណុច** របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

- យើងមានច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួង ស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

## ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឱ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

## គ. សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឱ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឱ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

## ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។

- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឱ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅខែកក្កដា ឆ្នាំ ២០២៣

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួម ដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឱ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបានត្រឹមត្រូវ។

៩. បន្តរៀបចំវិធានការ "គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១០. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១១. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

១២. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ...........ខែ.......ឆ្នាំ ថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០២៣

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ជូ_ប៊ុនអេង

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារគ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**"ដើម្បីជូនជ្រាប"**

-ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ៥៤លើក) មនុស្សចំនួន ៧៧៦នាក់ (ស្រី ២៤២នាក់)

| ស្ថាប័ន សម្របសម្រួល | សកម្មភាព |
| --- | --- |
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | ▪ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញ<br>○ ក្នុងពិធីបើកវគ្គបណ្តុះបណ្តាល ស្តីពីការវាយតម្លៃតាមដាន ការចល័តរបស់ជនទេសន្តរប្រវេសន៍តាមច្រកព្រំដែនកម្ពុជាជាមួយនិងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ក្នុងខេត្តស្ទឹងត្រែង។<br>○ ក្នុងពិធីបិទវគ្គបណ្តុះបណ្តាល ស្តីពីការវាយតម្លៃតាមដាន ការចល័តរបស់ជនទេសន្តរប្រវេសន៍តាមច្រកព្រំដែនកម្ពុជាជាមួយនិងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ក្នុងខេត្តស្ទឹងត្រែង។<br>○ ចូលរួមកម្មវិធីសំណេះសំណាលជាមួយក្រុមស្ត្រីជាគ្រូបង្រៀនគ្រូពេទ្យ និងថ្នាក់ដឹកនាំអនុសាខា សមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ ខេត្តបាត់ដំបង សមាសភាពក្នុងកម្មវិធីមានចំនួន ២២៥រូប។<br>▪ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញ<br>○ ក្នុងពិធីបើកវគ្គបណ្តុះបណ្តាល ស្តីពីការវាយតម្លៃតាមដាន ការចល័តរបស់ជនទេសន្តរប្រវេសន៍តាមច្រកព្រំដែនកម្ពុជាជាមួយនិងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ក្នុងខេត្តស្ទឹងត្រែង។<br>○ ក្នុងពិធីបិទវគ្គបណ្តុះបណ្តាល ស្តីពីការវាយតម្លៃតាមដាន ការចល័តរបស់ជនទេសន្តរប្រវេសន៍តាមច្រកព្រំដែនកម្ពុជាជាមួយនិងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ក្នុងខេត្តស្ទឹងត្រែង។<br>▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**<br>- លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ១៣ច្បាប់ លិខិតចូល ១៦ច្បាប់។<br>- លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ១៤ច្បាប់ លិខិតចូល ១០ច្បាប់។<br>- រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុ រៀងរាល់កិច្ចប្រជុំ។<br>- បូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ និងខែមិថុនា ឆ្នាំ២០២៣ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- បូកសរុបរបាយការណ៍ប្រចាំខែមិថុនា ឆ្នាំ២០២២ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។<br>- ប្រមូលរបាយការណ៍ពីអន្តរក្រសួង ស្ថាប័ន និងរាជធានី/ខេត្តទាំង២៥។ |

| | |
|---|---|
| | - រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។<br>- ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណាគារវីគី។<br>- គ្រប់គ្រងទំព័រហ្វេសប៊ុក របស់លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។<br>- គ្រប់គ្រងទំព័រហ្វេសប៊ុក របស់លោកជំទាវអគ្គលេខាធិការ គជ.ប.ជ.។<br>- ព័ត៌មានស្រាវជ្រាវ ពីគេហទំព័រព័ត៌មាននានា រក្សាទុកក្នុងបណ្ណាល័យ wiki ncct convert ជាPDF បានចំនួន៧៥ច្បាប់ និងបានចងក្រងជាសៀវភៅដាក់ជូនលោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងជូនលោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ គ.ជ.ប.ជ។<br>- អាប់ឡូតរូបភាពសកម្មភាព គ.ជ.ប.ជ និង គ.ខ.ប.ជ ចូលបណ្ណាល័យរូបភាពក្នុងប្រព័ន្ធ Wiki បានចំនួន៤០សកម្មភាព។<br>▪ **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់**<br>- លោកប្រធាន និងលោកអនុប្រធានក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់៖<br>○ បានចូលរួមសិក្ខាសាលាបណ្តុះបណ្តាល ស្តីពីការសិក្សាលើការចល័តរបស់ជនទេសន្តប្រវេសន៍តាមច្រកនៃព្រំដែនកម្ពុជា/សាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នៅសណ្ឋាគារ Angkor Meas Hotel ខេត្តស្ទឹងត្រែង។<br>○ បានបន្តចុះសិក្សាស្រាវជ្រាវ សម្ភាសពលករចំណាកស្រុកនៅស្រុកសៀមបូក ស្រុកសៀមប៉ាង ស្រុកបុរីអូរស្វាយសែនជ័យ ច្រកទ្វារអន្តរជាតិត្រពាំងគ្រៀល និងច្រករបៀង នៅខេត្តស្ទឹងត្រែង ក្រោមកិច្ចសហការគាំទ្រដោយអង្គការIOM ។<br>▪ **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**<br>- ឯកឧត្តម អគ្គលេខាធិការរងទទួលបន្ទុក និងលោកប្រធានក្រុមជំនួយកិច្ចការការពារជនរងគ្រោះ បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ដើម្បីបញ្ចប់សេចក្តីព្រាងសូចនាករ និងផែនការសកម្មភាព ស្តីពីសុខភាពជនទេសន្តប្រវេសន៍ ឆ្នាំ២០២៣-២០២៥ ក្រោមអធិបតីភាព ឯកឧត្តម ស៊ា ហ៊ួង រដ្ឋលេខាធិការ ក្រសួងសុខាភិបាល នៅខេត្តកំពង់ចាម។<br>- ឯកឧត្តម អគ្គលេខាធិការរងទទួលបន្ទុក បានអញ្ជើញចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការរៀបចំផែនការថវិកា ឆ្លើយតបលើការអនុវត្តន៍អនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារ នៃអង្គការសហប្រជាជាតិ ក្រោមអធិបតីភាព ឯកឧត្តម ម៉ែន សុចិត្រ រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តកំពង់ចាម។<br>- លោកអនុប្រធានក្រុមជំនួយកិច្ចការការពារជនរងគ្រោះ៖ |

- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ និងផ្ទៀងផ្ទាត់របាយការណ៍សិក្សាស្រាវជ្រាវវិភាគអំពីស្ថានភាពការកេងប្រវ័ញ្ចលើកុមារនៅកម្ពុជា នៅទន្លេបាសាក់២ រាជធានីភ្នំពេញ។
- បានចូលរួមចុះប្រមូលទិន្នន័យជនទេសន្តរប្រវេសន៍ នៅក្នុងស្រុកសៀមប៉ាង ស្រុកអូរស្វាយ ស្រុកសៀមបូក ខេត្តស្ទឹងត្រែ។
- បានចូលរួមកិច្ចប្រជុំពិនិត្យ និងផ្តល់ធាតុចូលលើសេចក្តីព្រាងទី២ របាយការណ៍ វិភាគបន្ទុកចំណាយ និងផលចំណេញ សេចក្តីព្រាងច្បាប់ ស្តីពីកុមារ ក្រោមអធិបតីភាព ឯកឧត្តម យៀប ម៉ាលីណូ អគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយសង្គម ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅសាលប្រជុំទីស្តីការក្រសួងសង្គមកិច្ច។

**▪ ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ**

- លោកជំទាវ អគ្គលេខាធិការរងទទួលបន្ទុក និងលោកប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ បានអញ្ជើញចុះពិនិត្យតាមដានការបង្រៀនវគ្គបណ្តុះបណ្តាលអំពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងការសម្អាតសំលុយកខ្វក់ និងសេដ្ឋកិច្ចវិច័យ នៅស្រុកភ្នំព្រឹក ខេត្តបាត់ដំបង។
- លោកជំទាវ អគ្គលេខាធិការរងទទួលបន្ទុក បានអញ្ជើញ៖
  - ដឹកនាំកិច្ចប្រជុំពិភាក្សា ការរៀបចំ TOT និង Training Guide តាមការស្នើសុំរបស់អង្គការដៃគូ ដើម្បីឱ្យវគ្គបណ្តុះបណ្តាល គោរពតាមស្តង់ដាររួមមួយរបស់ គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ។
  - ចូលរួមកិច្ចប្រជុំក្រុមការងារសហប្រតិបត្តិការអន្តរជាតិ និងក្រុមការងារខេមមីតកម្ពុជា ដែលបានរៀបចំដោយក្រសួងកិច្ចការនារី ដោយមានការគាំទ្រពីអង្គការអន្តរជាតិទេសន្តរប្រវេសន៍ នៅភោជនីដ្ឋាន ទន្លេបាសាក់២។
- លោកស្រី អនុប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ បានចូលរួមកិច្ចប្រជុំឆ្លងសេចក្តីព្រាងវិធានការទូទៅ ស្តីពីការកសាងចលនាប្រជាការពារក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ។

**▪ ក្រុមជំនួយកិច្ចការយុត្តិធម៌**

- ឯកឧត្តម អគ្គលេខាធិការរងទទួលបន្ទុក បានអញ្ជើញចូលរួមពិធីអបអរសាទរទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ប្រធានបទ «អ្វីៗដើម្បីប្រជាជនជាចម្បង បញ្ឈប់ការរើសអើង មាក់ងាយអ្នកញៀនគ្រឿងញៀន ពង្រឹងការងារអប់រំបង្ការ» ក្រោមអធិបតីភាព សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។

**▪ ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍**

- លោកអនុប្រធានក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍

| | |
|---|---|
| | ○ បានចូលរួមសិក្ខាសាផ្សព្វផ្សាយដាក់ឱ្យអនុវត្តកញ្ចប់អប់រំមាតាបិតាស្តីពីការចិញ្ចឹម បីបាច់កូនតូច ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម បណ្ឌិតសភាចារ្យ ហង់ ជួនណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា នៅសណ្ឋាគារភ្នំពេញ។<br>○ បានចូលរួមសិក្ខាសាលាបណ្តុះបណ្តាល ស្តីពីការសិក្សាលើការចល័តរបស់ជនទេសន្តប្រវេសន៍តាមច្រកនៃព្រំដែនកម្ពុជា/សាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នៅសណ្ឋាគារ Angkor Meas Hotel ខេត្តស្ទឹងត្រែង។<br>○ បានបន្តចុះសិក្សាស្រាវជ្រាវ សម្ភាសពលករចំណាកស្រុកនៅស្រុកសៀមបូក ស្រុកសៀមប៉ាង ស្រុកបុរីអូរស្វាយសែនជ័យ ច្រកទ្វារអន្តរជាតិត្រពាំងគ្រៀល និងច្រករបៀង នៅខេត្តស្ទឹងត្រែង ក្រោមកិច្ចសហការគាំទ្រដោយអង្គការIOM ។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ៣០លើក អ្នកចូលរួមសរុបចំនួន ៧៣៥នាក់ (ស្រី ២៦៨នាក់)** | |
| **ខេត្តកណ្តាល** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានបើកកិច្ចប្រជុំបូកសរុបលទ្ធការងារប្រចាំខែចំនួន០២លើក អ្នកចូលរួមចំនួន១១១នាក់ ស្រី៤២នាក់។<br>- ក្រុមការងារក្រុង-ស្រុក បានរៀបចំប្រជុំប្រចាំខែមេសា ចំនួន០៦លើក អ្នកចូលរួមចំនួន១៦៩នាក់ ស្រី៧៤នាក់។ |
| **ខេត្តសៀមរាប** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំឆមាសទី១ ឆ្នាំ២០២៣ ចំនួន០១លើក អ្នកចូលរួមចំនួន៥៩នាក់ ស្រី៣៩នាក់។<br>- ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ស្រុក បានរៀបចំកិច្ចប្រជុំប្រចាំខែចំនួន០៨លើក អ្នកចូលរួមចំនួន២១៣នាក់ ស្រី៨៨នាក់។ |
| **ខេត្តកំពត** | - បានរៀបចំកិច្ចប្រជុំប្រចាំខែមិថុនាចំនួន០១លើក អ្នកចូលរួមចំនួន១៩នាក់ ស្រី១៨នាក់។ |
| **ខេត្តឧត្តរមានជ័យ** | - ប្រជុំគណៈកម្មាធិការពិគ្រោះយោបល់លើកិច្ចការស្ត្រី និងកុមារចំនួន០១លើក អ្នកចូលរួមចំនួន១៧នាក់។ |
| **ខេត្តព្រៃវែង** | - បានរៀបចំកិច្ចប្រជុំប្រចាំខែ និងឆមាសទី១ ឆ្នាំ២០២៣ ចំនួន០២លើក អ្នកចូលរួមចំនួន១៣៨នាក់។ |
| **ខេត្តស្វាយរៀង** | - បានរៀបចំកិច្ចប្រជុំប្រចាំខែមិថុនាចំនួន០១លើក អ្នកចូលរួមចំនួន០៩នាក់ ស្រី០៧នាក់។ |